**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

*រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨*

**ផ្ញើជូន**

**ឯកឧត្តម សាម៉ាក់ ស៊ុនថារ៉ាវេត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រថៃ**

ឯកឧត្តម,

ដំបូងខ្ញុំសូមថ្លែងអំណរគុណ និងការសប្បាយរីករាយដែលឯកឧត្តម និងខ្ញុំបានពិភាក្សាគ្នាតាមទូរស័ព្ទ នាយប់ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៨ កន្លងមក ហើយដែលសំខាន់យើងទាំងពីរនាក់តំណាងអោយរដ្ឋទាំងពីរ នៅតែអះអាងពីការបន្តរិតចំណងមិត្តភាពសហប្រតិបត្តិការជិតខាងល្អ និងដោះស្រាយបញ្ហាតាមរយះការចរចា ព្រមទាំងកំណត់កាលបរិច្ឆេទសំរាប់ការចរចារវាងឯកឧត្តមផ្ទាល់ ជាមួយឯកត្តម ទៀ បាញ់ នៅថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៨ ខាងមុខនេះ ។ ក្នុងពេលពិភាក្សាតាមទូរស័ព្ទនោះ ខ្ញុំបានស្នើឯកឧត្តមអោយដកកងទ័ពចេញពីតំបន់វត្តកែវសិក្ខាគីរីស្វារៈ ( ហៅវត្តប្រាសាទព្រះវិហារ ) និងក្បែរប្រាសាទព្រះវិហារនិងធ្វើអោយសភាព-ការណ៍វិលទៅរកភាពដើមដូចមុនថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៨ វិញ ។ ប៉ុន្តែជាអកុសលនៅព្រឹកថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨ នេះ សភាពការណ៍មានការវិវត្តន៍អាក្រក់បន្ថែមទៀត ដោយទាហានថៃបង្កើនចំនួននៅក្នុងតំបន់វត្តកែវសិក្ខាគីរីស្វារៈ ( ហៅវត្តប្រាសាទព្រះវិហារ ) និងក្បែរប្រាសាទព្រះវិហារ ព្រមទាំងមានប្រជាជនជាបាតុករថៃថែមទៀត ។ សភាពការណ៍នេះអាក្រក់ណាស់សំរាប់ទំនាក់ទំនងរវាងប្រទេសយើងទាំងពីរ ដែលខ្ញុំសូមស្នើឯកឧត្តមមេត្តាចាត់វិធានការ ដើម្បីបន្ធូរបន្ថយភាពតានតឹង និងជាថ្មីម្តងទៀត ស្នើឯកឧត្តមបញ្ជាអោយដកកងទ័ពថៃចេញពីតំបន់វត្តកែវសិក្ខាគីរីស្វារៈ ( ហៅវត្តប្រាសាទព្រះវិហារ ) និងក្បែរប្រាទសាទព្រះវិហារដែលកងទ័ពទាំងនេះបានចូលមកពីថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៨ ដែលមកដល់ពេលនេះមិនគ្រាន់មិនព្រមដកថយប៉ុណ្ណោះទេ តែបែរជាបង្កើនចំនួនថែមទៀត ។

សូមឯកឧត្តមនាយករដ្ឋមន្ត្រីទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ហ៊ុន សែន